# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

<u>កិច្ចព្រមព្រៀងរវាង</u>

**នាយកតំណាងក្រុមហ៊ុន អិម ជេ ប៊ែក(ខេមបូឌា) ខូអិលធីឌី**

**និងតំណាងកម្មករប្រតិភូបុគ្គលិកនិងប្រធានក្រុមប្រចាំក្រុមហ៊ុន**

នៅថ្ងៃទី១៨ ខែមករាឆ្នាំ២០២១វេលាម៉ោង១និង៣៨នាទីរសៀលនៅក្នុងរោងចក្រអិមជេប៊ែក(ខេមបូឌា)ខូអិលធីឌីមានកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុននិងតំណាងកម្មករនិយោជិត។

នៅក្នុងអង្គប្រជុំនោះនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះខាតវត្ថុធាតុដើមពីប្រទេសដែលផ្គត់ផ្គង់វត្ថុធាតុដើមដោយសារប្រទេសនោះរងផលប៉ះពាល់

ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរខូវីដ-19(COVID-19)។ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន៥១នាក់ស្រី៣៨នាក់ក្នុងចំណោមកម្មករនិយោជិតសរុប១៥៥នាក់ស្រី៩៨នាក់)ក្នុងរយៈពេល៦០ថ្ងៃគិតចាប់ពីថ្ងៃទី២០ខែមករាឆ្នាំ២០២១។ដោយក្នុងអំឡុងរយៈពេលព្យួរការងារនេះកម្មករនិយោជិតបានឯភាពទទួលការផ្តល់នៅប្រាក់ឈ្នួល៣០ដុល្លាសហរដ្ឋអាមេរិច។

**ប្រាក់ឧបត្ថមក្នុងអំឡុងពេលព្យួរការងារនេះនិងបើកជូនបងប្អូនកម្មករនៅថ្ងៃទី១០ខែបន្ទាប់។**

អង្គប្រជុំបានចប់វេលាម៉ោង២និង៤០នាទីរសៀលនាថ្ងៃខែដដែលប្រកបដោយបរិយាកាសរីករាយនិងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃចន្ទ ទី៧កើត ខែមាឃ ឆ្នាំជូតទោស័ក ព.ស២៥៦៤

ព្រះសីហនុថ្ងៃទី២០ ខែមករា ឆ្នាំ២០២១

**ភាគីតំណាងក្រុមហ៊ុន**

**ភាគីតំណាងកម្មករនិយោជិត**

